# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Mar-2012, 13:25
CMS/CFO: Kauv Keoratanak


## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ទាក់ទងនឹងសក្ខីកម្មរបស់សាក្សី TCE-38 និង TCE-44**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្ដី អៀង សារី**

អាង ឧត្ដម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ា ឧត្ដារ**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង ធូ មុណី

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“ក្រុមមេធាវីការពារក្តី”) សូមធ្វើការឆ្លើយតប ទៅនឹងសេចក្តីជូនដំណឹងរបស់ ក.ស.ព ដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ទាក់ទងនឹងសក្ខីកម្ម របស់សាក្សី TCE-38 និង TCE-44[1]។ ចម្លើយតបនេះត្រូវតែធ្វើឡើងជាចាំបាច់ ដោយហេតុថា ទោះបីជា ឯកសាររបស់ ក.ស.ព បានដាក់ជាចំណងជើងថា “សេចក្តីជូនដំណឹង” និងចាប់ផ្តើមដោយចំណងជើងថា “ចម្លើយតប” ក៏ដោយ ក៏ឯកសារនេះ តាមខ្លឹមសាររបស់វា គឺជាសំណើសុំស្តាប់ចម្លើយសាក្សីជំនាញ TCE-38 នៅក្នុងពេលមួយជាក់លាក់តាមរយៈប្រព័ន្ធសោតទស្សន៍[2]។ ក្នុងករណីអង្គជំនុំជម្រះអនុញ្ញាតឲ្យ សាក្សីជំនាញ TCE-38 ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍មែននោះ វានឹងរំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការតទល់សាក្សីជំនាញ TCE-38 រូបនេះ និងសិទ្ធិទទួលការជំនុំជម្រះនៅចំពោះមុខ ជាពិសេស ដោយពិចារណាឃើញថា ភស្តុតាងគួរឲ្យជឿជាក់ពុំបានលើកឡើងឲ្យអង្គជំនុំជម្រះសាលាដំបូង អាចពិនិត្យឃើញឲ្យបានច្បាស់លាស់ ថាតើ នៅក្នុងករណីនេះ ការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធ សោតទស្សន៍នេះ ចាំបាច់ត្រូវធ្វើឡើង ដើម្បីជួយសម្រួលដល់សាក្សីជំនាញ TCE-38 ដោយពុំមាន ហានិភ័យប៉ះពាល់ដល់លោក អៀង សារី ដែរ ឬយ៉ាងណានោះទេ។ ដោយហេតុថា សំណើរបស់ ក.ស.ព ប៉ះពាល់ដល់សិទ្ធិមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូច្នេះ ក្រុមមេធាវីការពារក្តីសូមធ្វើការឆ្លើយតប នៅពេលនេះ[3]។ ជារួម អង្គជំនុំជម្រះគួរតែបដិសេធចោល

[1] សេចក្តីជូនដំណឹងរបស់ ក.ស.ព ដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ទាក់ទងនឹងសក្ខីកម្មរបស់សាក្សី TCE-38 និង TCE-44 ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ E166/1 (“សេចក្តីជូនដំណឹងរបស់ ក.ស.ព”) កថាខណ្ឌ ៤។

[2] *សូមមើល* អនុស្សរណៈដែលត្រូវបានធ្វើបច្ចុប្បន្នភាព សម្រាប់សវនាការលើឯកសារលើកក្រោយ (ថ្ងៃទី ១២-១៩ ខែ មីនា ឆ្នាំ ២០១២) ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២ E1 72/5 កថាខណ្ឌ ៦។

[3] សិទ្ធិក្នុងការដាក់ចម្លើយតបកើតចេញពីសិទ្ធិសមភាពរវាងគូភាគីក្តី និងសិទ្ធិទទួលបានគោលការណ៍ចំពោះមុខ។ គោលការណ៍នៃ សមភាពរវាងគូភាគីក្តីចែងថា៖ “សហមេមេធាវីការពារក្តី និងសហព្រះរាជអាជ្ញាត្រូវមានសមភាពក្នុងកិច្ចនីតិវិធីដើម្បីធានាថា ការអនុវត្តកិច្ចដំណើរការនីតិវិធីតុលាការមានភាពយុត្តិធម៌” *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ “ឌុច”* ០០១/១៨-០៧-២០០៧-អវតក/ អជសដ សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើ សុំឲ្យអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩ E90 កថាខណ្ឌ ៤។ គោលការណ៍នេះគឺជាគោលការណ៍ មូលដ្ឋាននៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនានា រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“កតិកាសញ្ញាអន្តរជាតិ”) (មាត្រា ១៤(១) ដែល អ.វ.តក៩.ក ត្រូវគោរពតាម អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះ រាជាណាចក្រកម្ពុជា។ គោលការណ៍នេះក៏ជាលក្ខខណ្ឌចែងនៅក្នុងវិធាន ២១(១)(ក) ដែលបញ្ញត្តិថា “ដំណើរការនីតិវិធីនៅក្នុង អង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានភាពយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ” ហើយត្រូវរក្សាបាននូវតុល្យភាពរវាង

សំណើសុំរបស់ ក.ស.ព ពីព្រោះថា សំណើសុំនេះពុំមានមូលដ្ឋានគួរឲ្យជឿជាក់អាចអនុញ្ញាតឲ្យសាក្សីជំនាញ TCE-38 មកផ្ដល់សក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ឡើយ យ៉ាងហោចណាស់បើពិនិត្យលើការលើកឡើងរបស់ ក.ស.ព នៅក្នុងលិខិតឆ្លើយឆ្លងជាមួយនឹងសាក្សីជំនាញ TCE-38 (សូមមើលកថាខណ្ឌ ១៤)។ ក្រុមមេធាវីការពារក្ដីយល់ស្របជាមួយនឹងជំហរបស់ ក.ស.ព ដែលបានលើកឡើងថា តាមរបាយការណ៍ TCE-44 ពុំស្ម័គ្រចិត្តមកផ្ដល់ភស្តុតាងទេនោះ អាស្រ័យហេតុនេះ សាក្សីជំនាញរូបនេះពុំគួរត្រូវបានចាប់បង្ខំឲ្យមកផ្ដល់សក្ខីកម្មឡើយ។ ក្រុមមេធាវីការពារក្ដីបានជំទាស់ដូចគ្នាទៅនឹងការតែងតាំង TCE-44 ជាសាក្សីជំនាញមកផ្ដល់សក្ខីកម្ម[4]។

## I. សាវតារ

1. នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ខ្លួនមានបំណងស្ដាប់សាក្សីជំនាញ TCE-38[5] ដែលបានស្នើឡើងដោយ ក.ស.ព[6]។ ក៏ប៉ុន្តែសាក្សីជំនាញរូប

---

សិទ្ធិរបស់ភាគីទាំងឡាយ...”។ *សូមមើល*សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្ដីអង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ D390/1/2/4 ដែលអង្គបុរេជំនុំជម្រះបានសម្រេចលើបញ្ហានេះ។ សិទ្ធិក្នុងការដាក់ចម្លើយតបទៅនឹងសំណើសុំដែលបានដាក់ដោយភាគីផ្សេងនោះ ក៏មានការជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានគោលការណ៍ចំពោះមុខ ដែលមានចែងនៅក្នុងវិធាន ២១(១)(ក)។ សិទ្ធិទទួលបានគោលការណ៍ចំពោះមុខ “ជាគោលការណ៍ មានន័យថាជាឱកាសសម្រាប់ភាគីនៅក្នុងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី បានដឹង និងផ្ដល់យោបល់លើគ្រប់ភស្តុតាង ឬ សេចក្ដីសង្កេតដែលបានដាក់ ទោះបីដោយសមាជិកឯករាជ្យណាមួយនៅក្នុងសេវាច្បាប់ជាតិក៏ដោយ ដោយមានគោលបំណងចង់ឲ្យមានអានុភាពលើសេចក្ដីសម្រេចរបស់តុលាការ” *Lobo Machado ទល់នឹង ប្រទេសព័រទុយហ្គាល់* តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ ១៥៧៦៤/៨៩ កថាខណ្ឌ ៣១។ យោងតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប៖ “វិធីនានាអាចឲ្យយើងជឿជាក់ ដែលច្បាប់ជាតិអាចបំពេញតាមលក្ខខណ្ឌនេះ។ ទោះបីជាយ៉ាងនេះក្ដី មិនថាជ្រើសរើសយកវិធីណាមួយឡើយ តុលាការត្រូវធានាថា ភាគីម្ខាងនឹងបានដឹងថាសេចក្ដីអង្កេតបានដាក់*និងមានឱកាសពិតប្រាកដក្នុងការដាក់យោបល់លើសេចក្ដីអង្កេតទាំងនេះ*” *Öcalan ទល់នឹង ប្រទេសទួគី* តុលាការសិទ្ធិមនុស្សអឺរ៉ុប ពាក្យសុំលេខ ៤៦២២១/៩៩ (២០០៥) កថាខណ្ឌ ១៤៦ (គូសបញ្ជាក់បន្ថែម)។

[4] *សូមមើល* ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំតែងតាំងអ្នកជំនាញ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ D281/2។ ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ D9/4/9។

[5] សម្ព័ន្ធសម្ងាត់ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ចុះថ្ងៃទី ២៥ ខែ តុលាឆ្នាំ ២០១១ E131/1.1។

នេះត្រូវបានជំទាស់ដោយក្រុមមេធាវីការពារក្តី[7]។

2. នៅថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តីបានទទួលការជូនដំណឹងក្រៅផ្លូវការ តាមរយៈក្រុមមេធាវីការពារក្តីមួយក្រុមថា មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានទំនាក់ទំនងក្រុមមេធាវីការពារក្តីលោក នួន ជា និងក្រុមមេធាវីការពារក្តីលោក ខៀវ សំផង ហើយបានជូនដំណឹងដល់ក្រុមទាំងពីរអំពីសាក្សីជំនាញ និងសាក្សីដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាថានឹងធ្វើការកោះហៅ ក្នុងនោះរួមទាំងសាក្សីជំនាញ TCE-38 ផងដែរ។ ក្រោយពីបានទទួលដំណឹងនេះភ្លាម ក្រុមមេធាវីការពរក្តីបានផ្ញើអ៊ីមែលទៅមន្ត្រីច្បាប់ជាន់ខ្ពស់ ដោយមានចម្លងជូនគ្រប់ភាគីទាំងអស់ ដើម្បីសួរ ថាតើព័ត៍មាននេះត្រឹមត្រូវដែរ ឬយ៉ាងណា ហើយថាតើមន្ត្រីច្បាប់ជាន់ខ្ពស់អាចជូនដំណឹងដល់ភាគីថាតើសាក្សីជំនាញ TCE-38 បានយល់ព្រមថា គាត់នឹងមកផ្តល់សក្ខីកម្មដែរ ឬយ៉ាងណា[8]។

3. នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះសាលាដំបូងនឹងខិតខំស្តាប់ចម្លើយសាក្សីជំនាញ TCE-38 ក្នុងអំឡុងវគ្គសវនាការដេញដោលលើរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ ក៏ប៉ុន្តែខ្លួនពុំមានលទ្ធភាពបញ្ជាក់ថាតើសាក្សីជំនាញ TCE-38 អាចមានលទ្ធភាពចូលរួមបាន ឬ មិនបាននៅក្នុងខែ មករា ឬ កុម្ភៈ ឆ្នាំ ២០១២ ឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ខ្លួននឹងជូនដំណឹងដល់ភាគីអំពីលទ្ធភាពអាចចូលរួមរបស់សាក្សីជំនាញរូបនេះភ្លាម ក្រោយពីមានព័ត៌មានបន្ថែម[9]។

4. នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីបានបញ្ជូនបញ្ជីសំណួរជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង នៅមុនកិច្ចប្រជុំរៀបចំការជំនុំជម្រះក្រៅផ្លូវការ នាថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២។ ក្រុមមេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងជូនដំណឹងដល់ខ្លួន

---

[6] បញ្ជីសាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា តាមវិធាន ៨០ រួមទាំងឧបសម្ព័ន្ធ ១ ២ ៣ ៣ក ៤ និង ៥ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ E9/4.2។

[7] ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ E9/4.9។

[8] អ៊ីមែលពី Tanya Pettay ជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចំណងជើង "ក្រុមសាក្សីបន្ទាប់របស់អង្គជំនុំជម្រះ សាលាដំបូង" ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១១។

[9] អនុស្សារណៈនៃអង្គជំនុំជម្រះសាលាដំបូង៖ ក្រុមសាក្សី និងអ្នកជំនាញបន្ទាប់ដែលអង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ E155។

អំពីព័ត៌មានថ្មីៗ ថាតើសាក្សីជំនាញ TCE-38 នឹងមកផ្តល់សក្ខីកម្មក្នុងអំឡុងវគ្គសវនាការស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធទំនាក់ទំនងការងារ ថាតើសាក្សីជំនាញនេះត្រូវបានកោះហៅរួចហើយ ឬនៅ ថាតើនៅពេលណាទើបសាក្សីជំនាញនេះនឹងគ្រោងមកផ្តល់សក្ខីកម្ម និងថាតើការផ្តល់សក្ខីកម្មរបស់សាក្សីជំនាញមានរយៈពេលប្រហែលប៉ុន្មានដែរ[10]។

5. នៅពេលប្រជុំរៀបចំការជំនុំជម្រះក្រៅផ្លូវការមួយនាថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា សាក្សីជំនាញ TCE-38 នឹងពុំមកផ្តល់សក្ខីកម្មនៅក្នុងប៉ុន្មានសប្តាហ៍ខាងមុខនេះទេ ហើយក៏ពុំទាន់ត្រូវបានកោះហៅនៅឡើយដែរ។

6. នៅពេលប្រជុំរៀបចំការជំនុំជម្រះក្រៅផ្លូវការមួយនាថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា សាក្សីជំនាញ TCE-38 បានបញ្ជាក់ថា លោកមានលទ្ធភាពចូលរួមផ្តល់សក្ខីកម្មនៅចុងខែ មីនា ឆ្នាំ ២០១២ ក៏ប៉ុន្តែ តាមរយៈប្រព័ន្ធសោតទស្សន៍តែប៉ុណ្ណោះ។ ពុំមានការពន្យល់ណាមួយបានធ្វើឡើងថាហេតុអ្វីបានជាសាក្សីជំនាញ TCE-38 ពុំមានលទ្ធភាពចូលរួមដោយផ្ទាល់ និងអំពីលទ្ធភាពចូលរួមរបស់សាក្សីជំនាញរូបនេះ នាពេលក្រោយក្នុងឆ្នាំ ២០១២។ នៅក្នុងពេលប្រជុំនេះ សហមេធាវីការពារក្តីអន្តរជាតិ Michael G. Karnavas បានជំទាស់ទៅនឹងការស្តាប់សក្ខីកម្មសាក្សីជំនាញ TCE-38 តាមរយៈប្រព័ន្ធសោតទស្សន៍។ ក.ស.ព បានយល់ស្របថា វាជាការប្រសើរជាងប្រសិនបើសាក្សីជំនាញ TCE-38 អាចផ្តល់សក្ខីកម្មដោយផ្ទាល់បាន។

7. នៅពេលប្រជុំរៀបចំការជំនុំជម្រះក្រៅផ្លូវការមួយនាថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា សាក្សីជំនាញ TCE-38 បានបដិសេធមកផ្តល់សក្ខីកម្មដោយផ្ទាល់ ហើយអង្គជំនុំជម្រះសាលាដំបូង មិនខុសពីភាគីនានាផងដែរនោះ ចង់ឲ្យសាក្សីជំនាញរូបនេះមកផ្តល់សក្ខីកម្មដោយផ្ទាល់ដែរ ហើយកំពុងពិចារណាចំណាត់ការណាមួយដែលប្រសើរបំផុតនោះ។ ពុំមានការពន្យល់ណាមួយបានធ្វើឡើងថា ហេតុអ្វីបានជាសាក្សីជំនាញ TCE-38 ពុំអាចមកផ្តល់សក្ខីកម្មដោយផ្ទាល់បាននោះទេ។

8. នៅពេលប្រជុំរៀបចំការជំនុំជម្រះក្រៅផ្លូវការមួយនាថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ដោយហេតុថា សាក្សីជំនាញ TCE-

[10] អ៊ីមែលពី Tanya Pettay ជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចំណងជើង “សំណួរសម្រាប់កិច្ចប្រជុំរៀបចំការជំនុំជម្រះនាថ្ងៃសុកនេះ” ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២។

38 បានបដិសេធមកផ្ដល់សក្ខីកម្មដោយផ្ទាល់នោះ អង្គជំនុំជម្រះសាលាដំបូងនឹងចេញអនុស្សរណៈមួយ ស្នើឲ្យ ក.ស.ព ជូនដំណឹងដល់អង្គជំនុំជម្រះថាតើ ក.ស.ព នៅតែមានបំណងស្ដាប់សក្ខីកម្មសាក្សីជំនាញ TCE-38 ទៀតដែរ ឬយ៉ាងណា ហើយថាតើ ក.ស.ព ស្នើសុំឲ្យមានការស្ដាប់សក្ខីកម្មតាមទម្រង់មួយណានោះ។

9. នៅថ្ងៃទី ៦ ខែ កុម្ភៈ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដោយប្រគល់ភារកិច្ចក្នុងការសួរសំណួរទៅសាក្សីជំនាញ TCE-38 ជូនទៅ ក.ស.ព ហើយបានស្នើឲ្យ ក.ស.ព "ជូនដំណឹងមកអង្គជំនុំជម្រះ និងភាគីវិញ ក្នុងអំឡុងរយៈពេលបីសប្ដាហ៍ គិតចាប់ពីថ្ងៃនេះ ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ស្ដីពីការកំណត់ពេល និងនីតិវិធីនៃការស្ដាប់សក្ខីកម្មរបស់សាក្សីជំនាញ" TCE-38[11]។ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យ ក.ស.ព ជួបទាក់ទងជាមួយនឹងសាក្សីជំនាញ TCE-38 ក្នុងគោលបំណងនៃការបញ្ជាក់អំពីភាពអាចចូលរួមសវនាការរបស់សាក្សីជំនាញរូបនេះ និងដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការរៀបចំផែនការការងារ និងការកំណត់កាលបរិច្ឆេទនៃការស្ដាប់សក្ខីកម្មរបស់គាត់[12]។

10. នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ក.ស.ព បានដាក់សេចក្ដីជូនដំណឹងរបស់ខ្លួនជូនទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ទាក់ទងនឹងសក្ខីកម្មរបស់សាក្សីជំនាញ TCE-38 និង TCE-44 ដោយលើកឡើងថា៖ "គាត់មិនអាចធ្វើដំណើរមកកម្ពុជាក្នុងឆ្នាំ ២០១២ នេះដើម្បីផ្ដល់សក្ខីកម្មដោយផ្ទាល់បានទេ ដោយមូលហេតុនៃអាជីពដទៃផ្សេងទៀត។ គាត់បាននិយាយថា គាត់អាចធ្វើដំណើរបានក្នុងឆ្នាំ ២០១៣។ ប៉ុន្តែ សាក្សីជំនាញ TCE-38 បានយល់ព្រមផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមរយៈប្រព័ន្ធសោតទស្សន៍ (Video link) ក្នុងឆ្នាំ ២០១២"[13]។ សហព្រះរាជអាជ្ញាពុំបានផ្ដល់ភស្តុតាង ឬ ឯកសារសំអាងពាក់ព័ន្ធនឹងបញ្ហានេះឡើយ។ លិខិតឆ្លើយឆ្លងរវាង ក.ស.ព និងសាក្សីជំនាញ TCE-38 ពុំបានផ្ដល់ជូនភាគី ហើយក៏ពុំមាននៅក្នុងសំណុំរឿងផងដែរ។

## II. អង្គច្បាប់

### ក. សិទ្ធិតទល់ជាមួយនឹងសាក្សី

[11] ការស្ដាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44 ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១២ E166។

[12] *ដូចខាងលើ*។

[13] សេចក្ដីជូនដំណឹងរបស់ ក.ស.ព កថាខណ្ឌ ៣។

11. សិទ្ធិរបស់ជនជាប់ចោទនៅក្នុងការតទល់ ឬ ដេញដោលសួរសាក្សីដាក់បន្ទុកមកលើខ្លួន គឺជាសិទ្ធិមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលបានធានាដោយកិច្ចព្រមព្រៀង[14] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[15] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[16] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[17] ដែលព្រះរាជាណាចក្រកម្ពុជាត្រូវគោរពតាម អនុលោមតាមធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមាត្រា ៣១ បានចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"[18]។ សិទ្ធិនេះត្រូវបានចាត់ទុកថាជា "សិទ្ធិមូលដ្ឋាននៅក្នុងសញ្ញាណទំនើបនៃការជំនុំជម្រះដោយយុត្តិធម៌"[19] ហើយត្រូវបានទទួលស្គាល់ទាំងនៅក្នុងអំណាចច្បាប់ស៊ីវិលឡូ និងច្បាប់ខំមិនឡូ[20]។ នៅសហរដ្ឋអាមេរិក[21] និងបណ្តាប្រទេស

---

[14] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ("កិច្ចព្រមព្រៀង") មាត្រា ១៣ (១)។

[15] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ៣៥ ថ្មី។

[16] មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឲ្យចូលរួមក្នុងសវនាការ"។

[17] មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិចែងថា៖ "នៅក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖...(ង) ត្រូវមានការសួរចម្លើយ ឬ សុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក..."។

[18] *សូមមើល* រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ ១៩៩៩ មាត្រា ៣១។

[19] *R ទល់នឹង Hughes 2 N.Z.L.R 129, 148* ដែលបានដកស្រង់នៅក្នុង Ian Dennis *The Right to Confront Witnesses: Meanings, Myths and Human Rights*, CRIM. L.R. 255, 255 (2010)។ សិទ្ធិនេះ "ត្រូវបានយល់ស្របជា ទូទៅថាជាធាតុមូលដ្ឋានមួយនៃការជំនុំជម្រះដោយយុត្តិធម៌ ជាជាងសច្ចធារណ៍និរទោស" *ដូចខាងលើ*។

[20] *សូមមើល* មាត្រា ៦(៣)(ឃ) នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ("អនុសញ្ញាអឺរ៉ុប") ដែលមានបទប្បញ្ញត្តិមួយស្រដៀងនឹងមាត្រា ១៤(៣)(ឃ)នៃកតិកាសញ្ញាអន្តរជាតិ។ អនុសញ្ញាអឺរ៉ុបនេះត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋនៅអឺរ៉ុបស្ទើរតែទាំងអស់ និងអនុវត្តនៅទូទាំងប្រព័ន្ធតុលាការ រួមទាំងនៅក្នុងនីតិវិធីព្រហ្មទណ្ឌនៃប្រព័ន្ធរ៉ូម៉ែនណូ-ហ្សឺម៉ែនទីកផងដែរ។

[21] *សូមមើល* រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក វិសោធនកម្មលើកទី VI។

ផ្សេងទៀត វាគឺជាសិទ្ធិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ[22]។ សិទ្ធិនេះ "អាចឃើញមានមូលដ្ឋានលើសិទ្ធិចម្លងរបស់ជនជាប់ចោទ ប្រឆាំងនឹងសេចក្ដីសម្រេចដែលមានសំអាងហេតុមិនត្រឹមត្រូវ" និង "ជានីតិវិធីដ៏មានសារប្រយោជន៍សម្រាប់វាយតម្លៃភស្តុតាង ហើយអាចឲ្យតុលាការសម្រេចថាតើខ្លួនគួរទុកចិត្តដោយសុវត្ថិភាពលើភស្តុតាងនេះបានកម្រិតប៉ុនណាដែរ"[23]។

## ខ. សិទ្ធិទទួលបានការជំនុំជម្រះនៅចំពោះមុខ

12. សិទ្ធិរបស់ជនជាប់ចោទនៅក្នុងការទទួលបានការជំនុំជម្រះនៅចំពោះមុខ គឺជាសិទ្ធិមូលដ្ឋាននៅក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅចំពោះមុខខ្លួន នៅចំពោះមុខតុលាការ *និង*សាក្សីផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួន[24]។ សិទ្ធិនេះត្រូវបានធានាតាមរយៈច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[25] និងកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[26] ដែលប្រទេសកម្ពុជាត្រូវតែគោរពតាមអនុលោមតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន[27]។

## គ. វិធានដែលសក្ខីកម្មសាក្សីត្រូវធ្វើធ្វើឡើង*ចេញពីមាត់ផ្ទាល់* ក្នុងករណីដែល អាច ធ្វើទៅបាន

13. វិធាន ២៦(១)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") ចែងថា៖

> សក្ខីកម្មរបស់សាក្សី ឬ អ្នកជំនាញនៅក្នុងអំឡុងពេល...ជំនុំជម្រះ*ត្រូវធ្វើឡើងដោយមានវត្តមានរបស់បុគ្គលនោះផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន*។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ...អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យសាក្សីធ្វើសក្ខីកម្មតាមរយៈបច្ចេកវិទ្យាសោតទស្សន៍ ឬ ទូរទស្សន៍ ក្នុងករណីដែលបច្ចេកវិទ្យាបែបនេះអនុញ្ញាតឲ្យ...អង្គជំនុំជម្រះ និង ភាគីសាកសួរសាក្សីបាន នៅពេលដែលសាក្សីត្រូវឡើងធ្វើសក្ខីកម្ម ។

---

[22] STEFANO MAFFEI, THE EUROPEAN RIGHT TO CONFRONTATION IN CRIMINAL PROCEEDINGS: ABSENT, ANONYMOUS AND VULNERABLE WITNESSES 9 (ការបោះពុម្ពផ្សាយច្បាប់របស់ Europa ឆ្នាំ ២០០៦) ដកស្រង់រដ្ឋធម្មនុញ្ញអ៊ីតាលី និងអាល់បានី។

[23] Ian Dennis *The Right to Confront Witnesses: Meanings, Myths and Human Rights*, CRIM. L.R. 255, 255 (2010)។

[24] ចំពោះការបកស្រាយថា សិទ្ធិនេះរួមទាំងសិទ្ធិមានវត្តមាននៅពេលផ្ដល់សក្ខីកម្មរបស់សាក្សី *សូមមើល* Zigiranyirazo *ទល់នឹង រដ្ឋអាជ្ញា* ICTR-2001-73-AR73 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បន្ទំ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៦ ដូចបានពិភាក្សា*ខាងលើ*។

[25] ច្បាប់ អ.វ.ត.ក មាត្រា ៣៥(ថ្មី)(ឃ)។

[26] កតិកាសញ្ញាអន្តរជាតិ មាត្រា ១៤(៣)(ឃ)។

[27] *សូមមើល* រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ ១៩៩៩ មាត្រា ៣១។

បច្ចេកវិទ្យានេះមិនត្រូវអនុញ្ញាតឲ្យប្រើទេ ប្រសិនបើធ្វើឲ្យមានអន្តរាយធ្ងន់ធ្ងរ ឬ មិនស្រប ទៅនឹងសិទ្ធិការពារខ្លួន[28]។

## III. ឧទ្ទិករណ៍

### ក. សាក្សីជំនាញ TCE-38 ត្រូវផ្តល់សក្ខីកម្មដោយផ្ទាល់នៅ អ.វ.ត.ក។ ហេតុផលមិនចូលខ្លួនរបស់សាក្សីជំនាញរូបនេះ ខកខានមិនបានបំពេញលក្ខខណ្ឌណាមួយនៃវិធាន ២៦(១) ដែលត្រូវយកមកពិចារណា នៅពេលអនុញ្ញាតឲ្យផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍

14. អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសសាក្សីជំនាញ TCE-38 ឲ្យមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីជំនាញនៅក្នុងសំណុំរឿង ០០២/១[29]។ សាក្សីជំនាញរូបនេះត្រូវបានរំពឹងថា នឹងមកផ្តល់សក្ខីកម្មលើបញ្ហាជាច្រើន ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់នឹងរឿងក្តីដាក់បន្ទុកលើលោក អៀង សារី[30]។ ទោះបីជាយ៉ាងនេះក្តី សាក្សីជំនាញ TCE-38 បានអះអាងថា ខ្លួនពុំមានលទ្ធភាពចូលមកផ្តល់សក្ខីកម្មដោយផ្ទាល់ពេញមួយឆ្នាំ ២០១២ ហើយបានត្រឹមតែលើកឡើងថា លោក "អាច" មានលទ្ធភាពចូលមកផ្តល់សក្ខីកម្មនៅក្នុងឆ្នាំ ២០១៣[31]។ យុត្តិកម្ម/សេចក្តីដោះសារដែលសាក្សីជំនាញ TCE-38 បានលើកឡើង (យោងតាមអ្វីដែលយើងអាចពិនិត្យមើលតាមរយៈការលើកឡើងយ៉ាងច្បាស់លាស់ដោយ ក.ស.ព) ថាលោកមិនមានលទ្ធភាពចូលរួមនៅក្នុងឆ្នាំ ២០១២ គឺ "ដោយសារអាជីពដទៃផ្សេងទៀត"[32]។ ទោះបីជា សាក្សីជំនាញ TCE-38 ប្រហែលជាបាននិយាយច្រើន (ឬ តិចជាងនេះ) អំពីការដែលលោកមិនអាចមកចូលរួមក៏ដោយ ភាគីអាចដឹងអំពីករណីនេះច្បាស់ ក៏មានតែអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះដែលអាចសម្រេចលើបញ្ហានេះបាន តាមរយៈការបង្គាប់ក.ស.ព ឲ្យលាតត្រដាងអ៊ីមែល ឬ លិខិត និងកំណត់សម្គាល់ទាំងអស់ចេញស្តីពីការឆ្លើយឆ្លងដោយផ្ទាល់មាត់រវាង ក.ស.ព និង TCE-38 តែប៉ុណ្ណោះ។ ដោយសារហេតុនេះ និងជាពិសេស ដោយពិចារណាលើអាការៈរបស់ ក.ស.ព ពាក់ព័ន្ធនឹង TCE-38

---

[28] គូសបញ្ជាក់បន្ថែម។

[29] សម្ព័ន្ធសម្គាត់ កៈ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ចុះថ្ងៃទី ២៥ ខែ តុលាឆ្នាំ ២០១១ E131/1.1។

[30] សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដោយមានចំណុចនៃដីកាដំណោះស្រាយ - ក.ស.ព ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ E9/13.1។

[31] សេចក្តីជូនដំណឹងរបស់ ក.ស.ព កថាខណ្ឌ ៣។

[32] *ដូចខាងលើ*។

ក្រុមមេធាវីការពារក្តី សូមឆ្លៀតឱកាសនេះស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចេញដីកាចាត់របៀប កុំឲ្យមានការធ្វើទំនាក់ទំនង *តែរវាងភាគីតែម្ខាង* រវាង ក.ស.ព និង TCE-38។ ការធ្វើដូច្នេះ នឹងធានានូវគុណតម្លៃនៃកិច្ចដំណើរការនីតិវិធី ជាពិសេសនៅក្នុងការដេញដោលសាក្សីជំនាញ TCE-38 នេះ។

15. ដោយហេតុថា សាក្សីជំនាញ TCE-38 បានលើកឡើងថា ខ្លួនពុំមានលទ្ធភាពចូលរួមនៅក្នុងអំឡុងឆ្នាំ ២០១២ ក.ស.ព បានស្នើសុំឲ្យសាក្សីជំនាញរូបនេះផ្តល់សក្ខីកម្មតាមរយៈមធ្យោបាយសោតទស្សន៍[33]។ ការស្នើសុំបែបនេះផ្ទុយទៅនឹងវិធាន ២៦(១) នៃវិធានផ្ទៃក្នុង យ៉ាងហោចណាស់ពាក់ព័ន្ធទៅនឹងការដោះសារដែលសាក្សី TCE-38 បានលើកឡើង និងលើកឡើងបន្ត ដោយក.ស.ព ដែលតម្រូវឲ្យសាក្សីផ្តល់សក្ខីកម្មដោយផ្ទាល់ នៅពេលណាដែលអាចធ្វើទៅបាន។ ការផ្តល់សក្ខីកម្មតាមសោតទស្សន៍អាចធ្វើទៅបានដរាបណាសក្ខីកម្មនេះអន្តរាយ ឬ មិនស្របទៅនឹងសិទ្ធិរបស់ចុងចោទ។ ការផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ គឺជាបទដ្ឋាន ហើយសាក្សី ឬ ភាគីដែលស្នើសុំផ្តល់សក្ខីកម្មតាមបច្ចេកវិជ្ជាសោតទស្សន៍ ត្រូវចង្អុលបង្ហាញ ដោយយោងទៅតាមវិធាន ២៦(១) ថា: **ក.** សាក្សីផ្តល់សក្ខីដោយផ្ទាល់ក្នុងបន្ទប់សវនាការមិនអាចធ្វើទៅបាន, **ខ.** សក្ខីកម្មតាមសោតទស្សន៍ មិនធ្វើអោយអន្តរាយ ឬមិនស្របនឹងសិទ្ធិរបស់ចុងចោទ។ ក.ស.ព ខកខានមិនបានបង្ហាញថា ការស្តាប់សក្ខីកម្មសាក្សី TCE-38 នៅក្នុងបន្ទប់សវនាការមិនអាចធ្វើទៅបាននោះឡើយ។ កសព ក៏ខកខានថែមទៀតក្នុងការចង្អុលបង្ហាញថា ការស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ នឹងមិនបង្កអោយអន្តរាយដល់ ឬ មិនស្របនឹងសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលបានធានាសម្រាប់រូបគាត់ដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

### ១. ក.ស.ព ពុំបានបង្ហាញថាអ្នកជំនាញ TCE-38 ពុំអាចចូលខ្លួនមកផ្តល់សក្ខីកម្មផ្ទាល់នៅក្នុងបន្ទប់សវនាការបានឡើយ

16. ក.ស.ព ពុំបានបង្ហាញ ដូចការបង្គាប់របស់វិធាន ២៦(១)ថាយើងពុំអាចស្តាប់សក្ខីកម្មរបស់អ្នកជំនាញ TCE-38 ដោយផ្ទាល់បានឡើយ។ ក.ស.ព ពុំបានបង្ហាញថា អ្នកជំនាញ TCE-38 ពុំមានឆន្ទៈ ឬពុំមានលទ្ធភាពធ្វើដំណើរមក អ.វ.ត.ក ឡើយ កុំថាឡើយដល់ ក.ស.ព បានលើកហេតុផលណាមួយសមរម្យ។ តាមការពិត ក.ស.ព បានទទួលស្គាល់ថា អ្នកជំនាញ TCE-38 "បាន

[33] *ដូចខាងលើ* កថាខណ្ឌ ៥។

បញ្ជាក់ថា គាត់អាចធ្វើដំណើរមកកម្ពុជាក្នុងឆ្នាំ២០១៣”[34]។ ហេតុដូច្នេះ ពុំមានឡើយភស្តុតាងណាមួយច្បាស់លាស់ដែលបញ្ជាក់ថាអ្នកជំនាញ TCE-38 ពិតជាពុំមានវត្តមាន ឬមួយពុំមានឆន្ទៈក្នុងការធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដើម្បីចូលខ្លួនមកជួបតទល់ផ្ទាល់ជាមួយភាគី ដូចនីតិវិធីសម្រាប់អនុវត្តជាមួយសាក្សីផ្សេងឯទៀត លើកលែងតែក្នុងករណីពិសេសប៉ុណ្ណោះ។ ជាងនេះទៅទៀត ពុំមានឯកសារណាមួយគាំទ្រអំណះអំណាងរបស់អ្នកជំនាញ TCE-38 ដែលថាគាត់មានការងារវិជ្ជាជីវៈពេញមួយឆ្នាំ ២០១២ ដែលធ្វើឲ្យគាត់មិនអាចចូលមកបង្ហាញខ្លួនដើម្បីផ្តល់ភស្តុតាងលើសំណុំរឿង ០០២ ឡើយ[35]។ វាអាចជាការរំខានដល់អាជីពវិជ្ជាជីវៈរបស់គាត់ ឬដល់ជីវិតឯកជនរបស់គាត់ ប៉ុន្តែ ការរំខានទាំងនេះមិនអាចជាហេតុផលដែលមានសុពលភាព និងអាចទទួលយកបាននោះទេ។

17. តាមការសន្មត សាក្សី TCE-38 គឺជាអ្នកជំនាញអំពីបញ្ហាកម្ពុជា។ គាត់ធ្លាប់បានធ្វើដំណើរមកកម្ពុជាចំនួនជាច្រើនលើក។ គាត់ពុំមែនជាបុគ្គលដែលពុំធ្លាប់មកកម្ពុជា ឬពិបាកនឹងធ្វើដំណើរមកកម្ពុជាឡើយ។ គាត់អាចមានការងារវិជ្ជាជីវៈដែលមិនអនុញ្ញាតឲ្យគាត់មកកម្ពុជាបានភ្លាមៗមែន ប៉ុន្តែដោយមានការជូនដំណឹងជាមុនត្រឹមត្រូវ (ហើយគួររំឭកថា ដោយយោងលើការប្រាស្រ័យទាក់ទងការងារជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង សាក្សី TCE-38 អាចបានដឹងតាំងពីរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ ២០១១ ថាគាត់កំពុងត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្ម) ស្ទើរតែមិនអាចទាល់តែសោះដែលថា សាក្សី TCE-38 ពុំមានលទ្ធភាពធ្វើដំណើរមកកម្ពុជានៅពេលណាមួយក្នុងអំឡុងឆ្នាំ២០១២។ សាក្សី TCE-38 ទំនងហាក់ដូចជាពុំមានបំណងចូលខ្លួនមកផ្តល់សក្ខីកម្មផ្ទាល់ឡើយ។ តាមដែលមេធាវីការពារក្តីបានដឹង គឺថាគាត់ពុំបានបង្ហាញភស្តុតាងណាមួយដើម្បីបញ្ជាក់ថា គាត់ពុំមានលទ្ធភាពចូលខ្លួនមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងឆ្នាំ២០១២ បានឡើយ[36]។ ក្លាន ហ្វិត និង រម៉ាម យុន ដែលមានវ័យចំណាស់ និងមានជំងឺដម្កាត់ ត្រូវធ្វើដំណើរពីតំបន់ចុងកាត់

[34] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣។

[35] ដូចជើងទំព័រខាងលើ។

[36] ស្ថានភាពរបស់សាក្សីរូបនេះខុសពីស្ថានភាពរបស់សាក្សី ឡុង នរិន្ទ ដែលត្រូវបាវាយតម្លៃឃើញថា គាត់មិនអាចធ្វើដំណើរបាននោះទេ ដោយសារតែស្ថានភាពសុខភាពរបស់គាត់មិនអំណោយផល។ សូមមើលប្រតិចារឹក ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១១ E1/17.1 ទំព័រ៣១។ នៅក្នុងប្រតិចារឹកត្រង់ផ្នែកនេះ អង្គជំនុំជម្រះសាលាដំបូង កត់សម្គាល់ថា ឡុង នរិន្ទនឹងផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ពីព្រោះគាត់ជាមនុស្សចាស់ មិនរឹងប៉ឹង និងមានសុខភាពដុនដាបទៀតផង ហើយគាត់រស់នៅក្នុងតំបន់ដាច់ស្រយាល។

មាត់ញូកនៅខេត្តមណ្ឌលគិរីមកភ្នំពេញតាមផ្លូវគោក ដើម្បីផ្តល់សក្ខីកម្មក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី លើកទីមួយនៅខែ ធ្នូ ឆ្នាំ ២០១១ និងលើកទីពីរនៅខែ មករា ឆ្នាំ ២០១២។ ការធ្វើដំណើររបស់ពួកគាត់ស្មើរតែចំណាយពេលច្រើន ដូចការធ្វើដំណើរតាមយន្តហោះរបស់សាក្សី TCE-38 ដែរ ហើយការធ្វើដំណើររបស់ពួកគាត់ពិតជាមានភាពលំបាកលំបិន ជាងការធ្វើដំណើរតាមយន្តហោះរបស់សាក្សីTCE-38 ទៅទៀត។ សាក្សី TCE-38 ពុំគួរទទួលបានការយកចិត្តទុកដាក់ពិសេស ដោយសារតែគាត់បានអះអាងទាំងពុំបានលើកភស្តុតាងជាឯកសារណាមួយដើម្បីបញ្ជាក់ថា គាត់ពុំមានលទ្ធភាព ឬមានហេតុផលសមស្របក្នុងការពុំចង់ចូលខ្លួនមកផ្តល់សក្ខីកម្មឡើយ។

18. សាក្សី TCE-38 ធ្លាប់បានបញ្ជាក់ទៀតថាគាត់អាចមានវត្តមាននៅក្នុងឆ្នាំ ២០១៣ ដែលហួសថ្ងៃបរិច្ឆេទដែល ក.ស.ព បានស្នើសុំស្តាប់សក្ខីកម្មរបស់គាត់ជិត ៩ ខែ។ ក.ស.ព បានស្នើសុំស្តាប់សក្ខីកម្មរបស់គាត់នៅក្នុងខែ មេសា ឆ្នាំ ២០១២។ តាមរយៈបញ្ជីឈ្មោះសាក្សី និងកាលបរិច្ឆេទនៃថ្ងៃសម្រាកមិនធ្វើសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងនាពេលបច្ចុប្បន្ន សំណុំរឿង ០០២/០១ ទំនងហាក់ដូចជាពុំអាចបញ្ចប់ឱ្យបានមុនពេលនេះឡើយ។ បន្ថែមពីលើចំណុចនេះ ដោយហេតុថាសំណុំរឿង ០០២ កំពុងត្រូវបានជំនុំជម្រះដោយចៅក្រមដែលមានវិជ្ជាជីវៈ សំណួរដែលថានៅពេលណាទើបសាក្សីណាម្នាក់ចូលមកបង្ហាញខ្លួន ពុំមែនជាបញ្ហាចោទឡើយ។ អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការតាមដានស្តាប់អង្គហេតុ ដែលកើតចេញពីភស្តុតាងនានាដែលភាគីបានលើក ប្រសិនបើភស្តុតាងទាំងនោះត្រូវបានបង្ហាញតាមលំដាប់លំដោយច្បាស់លាស់។ ការអះអាងផ្សេងពីនេះចាត់ទុកជាពុំបានការ។

## ២. ក.ស.ព ពុំបានបង្ហាញថាការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ពុំធ្វើឱ្យខូចប្រយោជន៍ ឬពុំស្របនឹងសិទ្ធិរបស់លោក អៀង សារី ឡើយ

19. វិធាន ២៦(១) នៃវិធានផ្ទៃក្នុងពុំបានចែងជាក់លាក់ពាក់ព័ន្ធនឹងកាលៈទេសៈ ដែលការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍នឹងធ្វើឱ្យខូចប្រយោជន៍ ឬមិនស្របនឹងសិទ្ធិរបស់មេធាវីការពារក្តីឡើយ។ ការចង់ឱ្យមានការចូលខ្លួនមកផ្តល់សក្ខីកម្មផ្ទាល់ និងភាពចាំបាច់ដែលត្រូវការពារសិទ្ធិរបស់ជនជាប់ចោទ បានញ៉ាំងឱ្យតុលាការ *ពុំអចិន្ត្រៃយ៍* បង្កើតលក្ខខណ្ឌហ្មត់ចត់លើបញ្ហានេះ ដែលយើងគួរលើកយកមកពិនិត្យពិចារណា នៅពេលយើងធ្វើការវាយតម្លៃអំពីលទ្ធភាពនៃការអនុញ្ញាតឱ្យ

មានការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍[37]។ ដូចដែលយើងនឹងបង្ហាញ *ខាងក្រោម* សាក្សី TCE-38 និង ក.ស.ព ពុំបានបង្ហាញថា សាក្សី TCE-38 បំពេញលក្ខខណ្ឌណាមួយចាំបាច់ ដើម្បីទទួលបានការអនុញ្ញាតឲ្យផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ឡើយ។

20. នៅឯតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (“ICTY”) អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង *Tadić* គឺជាអង្គជំនុំជម្រះដំបូងមួយដែលបានដោះស្រាយបញ្ហានេះក្នុងឆ្នាំ ១៩៩៦។ អង្គជំនុំជម្រះនេះបានគូសបញ្ជាក់ថា “យើងមិនអាចបញ្ជាក់ឲ្យលើសពីនេះទៀតបានទេ ថាវិធានទូទៅតម្រូវឲ្យសាក្សីចូលខ្លួនមកកាន់អសនៈរបស់តុលាការអន្តរជាតិ”[38]។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង *Tadić* បានសម្រេចថាប្រព័ន្ធសោតទស្សន៍នឹងត្រូវបានអនុញ្ញាតនៅពេលលក្ខខណ្ឌចំនួន២ត្រូវបានបំពេញ៖ លក្ខខណ្ឌទីមួយ គេត្រូវតែបង្ហាញថា សក្ខីកម្មរបស់សាក្សីពិតជាមានសារៈសំខាន់គ្រប់គ្រាន់ដែលធ្វើឲ្យពុំមានភាពយុត្តិធម៌ នៅពេលអនុវត្តកិច្ចដំណើរការនីតិវិធីដោយពុំមានសក្ខីកម្មនោះ ហើយលក្ខខណ្ឌទីពីរ គេត្រូវបញ្ជាក់ថាសាក្សីពុំមានលទ្ធភាព ឬពុំមានឆន្ទៈក្នុងការចូលមកបង្ហាញខ្លួននៅតុលាការ[39]។ អង្គជំនុំជម្រះនេះក៏បានលើកសំអាងហេតុទៀតថា “ថ្វីបើសក្ខីកម្មដែលផ្តល់តាមរយៈប្រព័ន្ធសោតទស្សន៍ មានទម្ងន់ជាងសក្ខីកម្មជាលាយលក្ខណ៍អក្សរក៏ដោយ ក៏ពុំមានទម្ងន់ដូចសក្ខីកម្មដែលសាក្សីបានចូលខ្លួនមកផ្តល់នៅក្នុងបន្ទប់សវនាការផ្ទាល់ឡើយ”[40]។

21. បន្ទាប់ពីមានសេចក្តីសម្រេចខាងលើ វិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICTY ត្រូវបានធ្វើវិសោធនកម្មដើម្បីអនុញ្ញាតឲ្យមានការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍។ វិធាន ៨១ *ស្ទួន* នៃ

---

[37] មាត្រា ៣៣ ថ្មីនៃច្បាប់បង្កើត អ.វ.ត.ក ចែងថា ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

[38] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Tadić*, លេខសំណុំរឿង IT-94-I-T, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីស្នើសុំកោះហៅ និងការពារសាក្សីរបស់មេធាវីការពារក្តី និងស្តីពីការផ្តល់ភស្តុតាងតាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ (“សេចក្តីសម្រេចលើបញ្ហាប្រព័ន្ធសោតទស្សន៍ក្នុងសំណុំរឿង *Tadić*”), កថាខណ្ឌ ១៨។

[39] ដូចជើងទំព័រខាងលើ។

[40] ដូចជើងទំព័រខាងលើ, កថាខណ្ឌ ២១។ *សូមមើលផងដែរ* សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Bagosora et al.*, លេខសំណុំរឿង ICTR-98-41-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំឲ្យមានការផ្តល់សក្ខីកម្មរបស់សាក្សី BT តាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៤, កថាខណ្ឌ ១៥៖ “សក្ខីកម្មរបស់សាក្សីដែលត្រូវបានស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិក ត្រូវប្រឈមនឹងការបាត់បង់ទម្ងន់នៃភស្តុតាង ច្រើនជាងការផ្តល់សក្ខីកម្មដោយផ្ទាល់នៅបន្ទប់សវនាការ ប្រសិនបើគុណភាពនៃការបញ្ជូនតាមរលកធាតុអាកាស ធ្វើឲ្យប៉ះពាល់ដល់ការវាយ តម្លៃរបស់អង្គជំនុំជម្រះទៅលើសាក្សី”។

វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICTY នាពេលបច្ចុប្បន្ន ដែលត្រូវបានអនុម័តកាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៧ ចែងថា៖ "តាមសំណើរបស់ភាគី ឬ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ចៅក្រម ឬអង្គជំនុំជម្រះអាចបង្គាប់ឲ្យអនុវត្តកិច្ចដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍ *ល្គឹកណា ការបង្គាប់នោះស្របទៅនឹងផលប្រយោជន៍នៃយុត្តិធម៌*"[41]។ សំណុំរឿងនានានៅឯតុលាការ ICTY នាពេលបច្ចុប្បន្ន ដែលត្រូវបានសម្រេចក្រោយពេលវិធានខាងលើត្រូវបានអនុម័ត បានចែងនូវ លក្ខខណ្ឌចំនួន៣ ដើម្បីសម្រេចថាតើការអនុញ្ញាតឲ្យមានការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ មានប្រយោជន៍ដល់យុត្តិធម៌ដែរឬទេ។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង *Stanišić & Simatović* ដាក់លក្ខខណ្ឌតម្រូវដូចខាងក្រោម៖

i. សាក្សីត្រូវតែជាអ្នកដែលគ្មានលទ្ធភាព ឬមានហេតុផលសមស្របក្នុងការពុំចង់ចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ

ii. សក្ខីកម្មរបស់សាក្សីត្រូវតែមានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីធ្វើឲ្យពុំមានភាពយុត្តិធម៌ដល់ភាគីស្នើសុំ ក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធីដោយពុំមានសក្ខីកម្មរបស់សាក្សី

iii. ជនជាប់ចោទពុំខូចប្រយោជន៍ នៅក្នុងការអនុវត្តសិទ្ធិតទល់នឹងសាក្សីរបស់ខ្លួន[42]

22. នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា ("ICTR") អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង *Nzabonimana* ទើបបានកំណត់លក្ខខណ្ឌស្រដៀងគ្នាចំនួន ៣ ៖

> លក្ខខណ្ឌទាំងនេះរួមមានការវាយតម្លៃអំពី (ក) សារៈសំខាន់នៃភស្តុតាង (ខ) អសមត្ថភាព ឬការពុំមានឆន្ទៈរបស់សាក្សីក្នុងការធ្វើដំណើរទៅ Arusha និង (គ) ថាតើអសមត្ថភាព និងការពុំមានឆន្ទៈមកផ្តល់សក្ខីកម្មនៅចំពោះតុលាការមានហេតុផលសមស្របដែរឬទេ។ ភាគីស្នើសុំមានបន្ទុកក្នុងការបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថា លក្ខខណ្ឌទាំងប៉ុន្មានខាងលើត្រូវបានបំពេញ។ ការស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធ

[41] គូសបញ្ជាក់បន្ថែម។

[42] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Stanišić & Simatović*, លេខសំណុំរឿង IT-03-69-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំស្តាប់សក្ខីកម្មសាក្សីតាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០, កថាខណ្ឌ ៨។

សោតទស្សន៍ គឺជាវិធានការពិសេសមួយដែលអនុវត្តទៅបាន លុះត្រាណាមានការបញ្ជាក់ហេតុផលត្រឹមត្រូវតាមច្បាប់ដោយសំអាងលើឯកសារត្រឹមត្រូវប៉ុណ្ណោះ[43]។

23. ក្នុងសំណុំរឿង *Nzabonimana*, មេធាវីការពារក្តីបានស្នើសុំឲ្យសាក្សីដែលជាអ្នកជំនាញមួយរូបផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក ឬទីក្រុងឡាអេ ដោយសារព្រួយបារម្ភអំពីបញ្ហាសុវត្ថិភាព រួមនឹងការគំរាមសម្លាប់ ប្រសិនបើសាក្សីនោះត្រឡប់ទៅ Arusha វិញ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា "ការលើកអំពីការព្រួយបារម្ភអំពីបញ្ហាសុវត្ថិភាពរបស់វេជ្ជបណ្ឌិត Thomson នៅក្នុងសេចក្តីថ្លែងការណ៍របស់គាត់ មានលក្ខណៈធ្ងន់ធ្ងរក្រៃលែង"[44] ប៉ុន្តែទោះជាដូច្នោះក្តី ក៏អង្គជំនុំជម្រះបានបដិសេធសំណើសុំផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ដោយហេតុថា ខ្លួនពុំជឿជាក់ថាសាក្សីអ្នកជំនាញរូបនេះស្ថិតនៅក្រោមកាលៈទេសៈពិសេស និងដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលឯកសារណាមួយ ដែលបញ្ជាក់អំពីការព្រួយបារម្ភអំពីបញ្ហាសុវត្ថិភាពឡើយ[45]។

24. នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន កសព មិនបង្ហាញនូវលក្ខខណ្ឌណាមួយសម្រាប់អនុញ្ញាតឲ្យមានការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ត្រូវបានបំពេញឡើយ។ ជាបឋម ដូចដែលយើងបានលើកយកមកពិភាក្សា*ខាងលើ* សាក្សី TCE-38 ពុំបានបង្ហាញថា គាត់ពុំអាចចូលខ្លួនមកផ្តល់សក្ខីកម្មផ្ទាល់ និងពុំមានលទ្ធភាព ឬមានហេតុផលសមស្របក្នុងការពុំចង់ចូលខ្លួនមកផ្តល់សក្ខីកម្មផ្ទាល់នៅ អ.វ.ត.ក ឡើយ។ ទីពីរ ថ្វីបើសាក្សី TCE-38 ហាក់ដូចជាសាក្សីអ្នកជំនាញដ៏សំខាន់

---

[43] *សំណុំរឿង រដ្ឋអាជ្ញា តទល់នឹង* *Nzabonimana*, សំណុំរឿងលេខ ICTR-98-44d-T, សេចក្តីសម្រេចលើសំណើបន្ទាន់របស់មេធាវីការពារក្តីស្នើសុំស្តាប់សក្ខីកម្មរបស់សាក្សីជំនាញ Dr. Susan Thomson តាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី ៩ ខែមីនា ឆ្នាំ ២០១១, កថាខណ្ឌ ១៦។

[44] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២១។

[45] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២២, ២៥។ *សូមមើលផងដែរ* សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Karadžić*, លេខសំណុំរឿង IT-95-5/18-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំកោះហៅ Berko Zečević មកផ្តល់សក្ខីកម្ម, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ១៩ ដែលតម្រូវឲ្យផ្តល់ឯកសារ៖ "ស្តីពីសំណើសុំធ្វើសក្ខីកម្មសាក្សីតាមរយៈប្រព័ន្ធសោតទស្សន៍ អង្គជំនុំជម្រះមិនបានទទួលឯកសារវេជ្ជសាស្ត្រណាមួយដើម្បីគាំទ្រដល់ការជំទាស់ដែលថា សាក្សីមានភាពទន់ខ្សោយផ្នែករាងកាយមិនអាចធ្វើដំណើរមកអង្គយុក្នុងសវនាការដើម្បីផ្តល់ភស្តុតាងបាន។ ហេតុនេះ អង្គជំនុំជម្រះពន្យារពេលក្នុងការសម្រេចលើសំណើនេះ ត្រង់ចំណុចមួយនេះ..."។ សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Ndindiliyimana និងអ្នកដទៃទៀត*, លេខសំណុំរឿង ICTR-00-56-T, សេចក្តីសម្រេចលើសំណើរបស់ Bizimungu ស្នើសុំឲ្យសាក្សី DE 4-12 ផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

មួយរូបសម្រាប់ ក.ស.ព ក៏ដោយ[46] ក៏ ក.ស.ព ពុំបានបង្ហាញថា សក្ខីកម្មរបស់គាត់មានសារៈសំខាន់រហូតធ្វើឱ្យមានភាពអយុត្តិធម៌ ប្រសិនបើកិច្ចកិច្ចនីតិវិធីដំណើរការដោយគ្មានសក្ខីកម្មរបស់គាត់។ ជាការពិត មានសាក្សីផ្សេងៗទៀតដែលបានគ្រោងផ្តល់សក្ខីកម្មលើសំណុំរឿង ០០២/០១ ដែលមានជំនាញ ក្នុងប្រភេទ និងកម្រិតដូចអ្នកជំនាញ TCE-38 ហើយដែលនឹងរំពឹងថាពួកគាត់នឹងផ្តល់សក្ខីកម្មលើប្រធានបទដូចគ្នានេះ[47]។

25. ចំណុចចុងក្រោយ ការផ្តល់សក្ខីកម្មរបស់សាក្សី TCE-38 តាមប្រព័ន្ធសោតទស្សន៍នឹងធ្វើឱ្យខូចប្រយោជន៍របស់លោក អៀង សារី។ ការផ្តល់សក្ខីកម្មនេះនឹងបង្អាក់ដល់សមត្ថភាពរបស់អ្នកជំនាញក្នុងការតទល់ជាមួយលោក អៀង សារី ឱ្យបានត្រឹមត្រូវ ដោយសារបច្ចេកវិទ្យាសោតទស្សន៍ពុំអាចជំនួសឱ្យការសួរដេញដោលសាក្សីដោយផ្ទាល់បានឡើយ។ ការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ពុំអនុញ្ញាតឱ្យអង្គជំនុំជម្រះ ឬភាគី មានឱកាសសង្កេត និងវាយតម្លៃអំពីភិនភាគបុគ្គលិកលក្ខណៈ អត្តចរិត និងឥរិយាបថរបស់សាក្សី ឱ្យបានដូចការផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការផ្ទាល់ឡើយ។ ដូចដែលតុលាការសហរដ្ឋអាមេរិកមួយ បានកត់សម្គាល់៖

> មានតែតាមរយៈការសួរដេញដោលផ្ទាល់ប៉ុណ្ណោះ ទើប [យើង] អាច ...ដឹងអំពីចំណុចខ្លាំង ឬចំណុចខ្សោយនៃសក្ខីកម្មរបស់សាក្សីបានដោយឥតខ្ចះចន្លោះ តាមរយៈការសង្កេតល្អិតល្អន់នូវឥរិយាបថ ការនិយាយស្តី និងការលើកដាក់សំឡេងរបស់សាក្សី។ សក្ខីកម្មដែលត្រូវបានថតជាវីដេអូ ដែលពិបាកសម្រាប់ការសួរដេញដោល គឺជំនួសបានយ៉ាងល្អនូវការផ្តល់សក្ខីកម្មផ្ទាល់ ដូចដែលយើងនឹងដឹង ប៉ុន្តែការផ្តល់សក្ខីកម្មបែបនេះគឺនៅតែជាវិធានការជំនួសប៉ុណ្ណោះ។ ទោះបីនាពេលបច្ចុប្បន្នយើងមានបច្ចេកវិទ្យាទំនើបក៏ដោយ ក៏ពុំអាចធ្វើឱ្យការចាក់ផ្សាយលក្ខណៈប្រព័ន្ធសោតទស្សន៍ទោមាត្រ (two-dimensional) មានភាពរស់រវើកបានឡើយ[48]។

ដោយពិចារណាឃើញថាបញ្ហានេះរមែងពាក់ព័ន្ធនឹងផ្នែកបច្ចេកទេស ដែលនឹងកាន់តែពិបាកតាមដានតាមរយៈប្រព័ន្ធសោតទស្សន៍ (ពិសេស ប្រសិនបើយើងជួបប្រទះបញ្ហាបច្ចេកទេសក្នុងអំឡុង

---

[46] ក.ស.ព ធ្លាប់បានស្នើសុំសួរសំណួរទៅសាក្សីរូបនេះចំនួន ១០ ម៉ោង។ *សូមមើល* វិធាន ៨០ របស់សហព្រះរាជអាជ្ញា, បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឧបសម្ព័ន្ធសម្ងាត់, ឯកសារ E9/4.2។

[47] ជាក់ស្តែង អ្នកជំនាញ TCE-11 មានអាជីព និងកម្រិតអប់រំដូចអ្នកជំនាញ TCE-38 ដែរ។

[48] សំណុំរឿង *Aguilar-Ayala ទល់នឹង* Ruiz, 973 F.2d 411, 419 (5th Cir. Tex. 1992)។

ពេលនៃការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍) ហេតុផលសម្រាប់ការផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការផ្ទាល់ ពាក់ព័ន្ធជាពិសេសទៅនឹងអ្នកជំនាញ។

26. ការផ្តល់សក្ខីកម្មដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ក៏អាចនាំមកនូវទម្ងន់មួយកម្រិតទៅដល់កិច្ចដំណើរការនីតិវិធីដែលពុំមាននៅក្នុងការផ្តល់សក្ខីកម្មពីចម្ងាយ ដាច់ឆ្ងាយពីបន្ទប់សវនាការ និងអ្នកចូលរួមសវនាការ[49]។ ការផ្តល់សក្ខីកម្មផ្ទាល់ជំរុញឲ្យសាក្សីប្រុងប្រយ័ត្ននូវពាក្យសម្តីរបស់ខ្លួន៖ សាក្សីអាចផ្តល់ពីចម្ងាយនូវសក្ខីកម្មមួយ ដែលខ្លួននឹងមិនផ្តល់ប្រសិនបើខ្លួនជួបប្រឈមផ្ទាល់ជាមួយជនជាប់ចោទ។ គាត់ក៏អាចកាន់តែមិនចង់ផ្តល់សក្ខីកម្មឥតភូតកុហក ដោយសារបែបបទនីតិវិធីតុលាការ។ ដូចដែលអ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ Sir Willam Blackstone បានពន្យល់អំពីសារៈសំខាន់នៃសក្ខីកម្មផ្ទាល់ ជាជាងសក្ខីកម្មជាលាយលក្ខណ៍អក្សរយ៉ាងដូច្នេះថា៖ "សាក្សីរមែងអាចផ្តល់សក្ខីកម្មជាឯកជន ដែលគាត់នឹងមានការអាម៉ាស នៅពេលផ្តល់សក្ខីកម្មនៅក្នុងតុលាការជាសាធារណៈ និងជាផ្លូវការ"[50]។

### ខ. សាក្សី TCE-38 ត្រូវចូលខ្លួនមកផ្តល់សក្ខីកម្មដោយផ្ទាល់នៅ អ.វ.ត.ក ដើម្បីគោរពសិទ្ធិជាសារវន្តរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់គាត់

27. ក្រៅពីធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការតទល់សាក្សី ការផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ក៏បានប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទៀតផង។ នៅឯតុលាការ ICTR សិទ្ធិសួរដេញដោលសាក្សីតាមរយៈការផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ ក៏ទាក់ទិននឹងសិទ្ធិមានវត្តមាននៅសវនាការផងដែរ។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTR នៅក្នុងសំណុំរឿង *Zigiranyirazo* បានយល់ឃើញថាការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ បានរំលោភទៅលើសិទ្ធិជាសារវន្តរបស់ Zigiranyirazo ក្នុងការមានវត្តមាននៅក្នុងសវនាការ[51] ដែលគាត់បានចោទ រួមទាំងសិទ្ធិក្នុងការទទួលបានការជំនុំ

---

49 យើងអាចសង្កេតចំណុចនេះ តាមរយៈការប្រៀបធៀបសក្ខីកម្មផ្ទាល់ដែលត្រូវបានផ្តល់នៅសវនាការមកទល់នឹងពេលនេះ ជាមួយសក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍របស់ ឡុង នរិន្ទ ដែលរមែងត្រូវបានរំខានដោយសំឡេងភ្លេងខ្ទរខ្ទារនៅក្បែរនោះ។

50 WILLIAM BLACKSTONE, COMMENTARIES ON THE LAWS OF ENGLAND 373-74 (VOLUME 3, 1768)។

51 សំណុំរឿង *Zigiranyirazo ទល់នឹង រដ្ឋអាជ្ញា*, លេខសំណុំរឿង ICTR-2001-73-AR73, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ, ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៦។

ជម្រះដោយមានវត្តមានរបស់សាក្សីដាក់បន្ទុក[52]។ នៅក្នុងសំណុំរឿងនោះ អង្គជំនុំជម្រះសាលាដំបូងបានផ្លាស់អសនៈនៃកិច្ចដំណើរការនីតិវិធីពី Arusha ទៅទីក្រុងឡាអេ ដើម្បីបានស្តាប់ដោយផ្ទាល់នូវសក្ខីកម្មរបស់សាក្សីដាក់បន្ទុកសំខាន់មួយរូប។ គេបានភ្ជាប់ Zigiranyirazo តាមប្រព័ន្ធសោតទស្សន៍ចូលទៅក្នុងកិច្ចដំណើរការនីតិវិធីពី Arusha ដោយហេតុថាបញ្ហាព្រួយបារម្ភផ្នែកភស្តុភារ បានរារាំងគាត់មិនឲ្យចូលរួមកិច្ចដំណើរការនីតិវិធីនៅទីក្រុងឡាអេ។ អង្គជំនុំជម្រះសាលាដំបូងបានផ្លាស់អសនៈសវនាការ ទៅទីក្រុងឡាអេដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ ដោយសារសារៈសំខាន់នៃ "ការវាយតម្លៃឲ្យបានត្រឹមត្រូវអំពីសាក្សីដាក់បន្ទុកសំខាន់"[53] និងជាក់ស្តែងដោយសារ "មន្ទិលរបស់ខ្លួនអំពីសមត្ថភាពរបស់ខ្លួនក្នុងការតាមដានឲ្យបានគ្រប់គ្រាន់នូវសក្ខីកម្មរបស់សាក្សីសំខាន់ តាមរយៈការប្រើប្រាស់ប្រព័ន្ធសោតទស្សន៍"[54]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថានេះជាការរំលោភលើសិទ្ធិរបស់ Zigiranyirazo ក្នុងការទទួលការបានជំនុំជម្រះដោយមានវត្តមានរបស់គាត់ ដោយបានលើកសំអាងហេតុថា ថ្វីបើសិទ្ធិនេះពុំមែនជាសិទ្ធិដាច់ខាតក៏ដោយ ក៏ការកំហិតសិទ្ធិនេះពុំមានហេតុផលសមស្រប និងមានភាពហួសហេតុក្រោមកាលៈទេសៈបែបនេះ[55]។ អង្គជំនុំជម្រះតុលាការកំពូលបានដកចេញនូវសក្ខីកម្មរបស់សាក្សីដែលផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ដោយផ្តល់សំអាងហេតុថាគេអាចសន្មតថាមានការប៉ះពាល់ផលប្រយោជន៍របស់ Zigiranyirazo[56] ។

28. នៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់គាត់ ដែលបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា[57] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[58] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[59] នឹងត្រូវរងការរំលោភបំពាន ប្រសិនបើសាក្សី TCE-38 ផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ដោយហេតុថា លោក

---

[52] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ១០។

[53] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ១៧។

[54] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ១៩។

[55] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ១៥-២២។

[56] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ២៤-២៥។

[57] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញចែងតម្រូវឲ្យមានការគោរពតាមកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[58] ច្បាប់បង្កើត អ.វ.ត.ក, មាត្រា ៣៥ ថ្មី (ឃ)។

[59] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤ (៣)(ឃ)។

អៀង សារី ដែលមានវ័យចំណាស់ និងមិនសូវមានសុខភាពរឹងមាំ ពុំមានលទ្ធភាពធ្វើដំណើរទៅជួបសាក្សី TCE-38 ដោយផ្ទាល់និងមានវត្តមានក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់គាត់តាមប្រព័ន្ធសោតទស្សន៍បានឡើយ។ ក.ស.ព ពុំបានបង្ហាញហេតុផលណាមួយឡើយ កុំថាឡើយមានហេតុផលគួរឲ្យជឿជាក់គ្រប់គ្រាន់ ដើម្បីផ្តល់ភាពត្រឹមត្រូវដល់ការកំហិតសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់គាត់ឡើយ។

**គ. សក្ខីកម្មរបស់សាក្សី TCE-38 តាមរយៈប្រព័ន្ធសោតទស្សន៍មានឧបសគ្គគតិយុត្តិ និង បញ្ហាភស្តុភារដែលធ្វើឲ្យការផ្តល់សក្ខីកម្មពុំអាចប្រព្រឹត្តទៅបាន និងដែលពុំតម្រូវឲ្យមានការពិចារណាល្អិតល្អន់ទៅលើសក្ខីកម្មទាំងនោះ**

29. ថ្វីបើអង្គជំនុំជម្រះសាលាដំបូងគួរផ្តល់សំអាងហេតុថា មានហេតុផលគួរឲ្យជឿជាក់គ្រប់គ្រាន់ដើម្បីកំហិតសិទ្ធិជាសារវ័ន្តក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី ដើម្បីតទល់ជាមួយសាក្សីដាក់បន្ទុក និងសិទ្ធិទទួលបានការជំនុំជម្រះដោយមានវត្តមានរបស់គាត់ក៏ដោយ ក៏ពុំទាន់ប្រាកដនៅឡើយថាតើ អ.វ.ត.ក មានអំណាចយុត្តាធិការក្នុងការរៀបចំឲ្យមានការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខាងក្រៅប្រទេសកម្ពុជាដែរ ឬទេ។ យោងតាមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង *Stanišić & Simatović* "ប្រព័ន្ធសោតទស្សន៍ដែលអនុញ្ញាតឲ្យសាក្សីមានវត្តមានផ្ទាល់ នៅទីតាំងណាមួយក្រៅសវនាការ នៅពេលផ្តល់សក្ខីកម្ម *គួរត្រូវបានចាត់ទុកជាការពង្រីកវិសាលភាពនៃបន្ទប់សវនាការទៅកាន់ទីតាំងរបស់សាក្សី*"[60]។ មិនដូចតុលាការ ICTY[61] តុលាការ ICTR[62] តុលាការឧក្រិដ្ឋកម្មអន្តរជាតិ [63] ឬតុលាការពិសេសសម្រាប់សៀរ៉ាឡេ

---

[60]សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Stanišić និង Simatović*, លេខសំណុំរឿង IT-03-69-T, សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំស្តាប់សក្ខីកម្មសាក្សីតាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០, កថាខណ្ឌ ១១ (គូសបញ្ជាក់បន្ថែម)។

[61] មាត្រា ២៩(២) នៃលក្ខន្តិកៈតុលាការ ICTY ចែងថា "រដ្ឋត្រូវអនុវត្តតាមដោយមិនពន្យារពេលនូវសំណើសុំជំនួយ ឬដីកាបង្គាប់ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង រួមមានដោយមិនកំណត់ត្រឹមតែ៖ ... (ខ) ការរៀបចំធ្វើសក្ខីកម្ម និងការបង្ហាញភស្តុតាង..."។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប លេខ 827 (S/RES/827(1993), ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣) ចែងថាក្រុមប្រឹក្សាសន្តិសុខ "សម្រេចថាការកំណត់ពីទីកន្លែងរបស់តុលាការអន្តរជាតិគឺជាកម្មវត្ថុនៃការសន្និដ្ឋានពីការរៀបចំយ៉ាងសមរម្យរវាងអង្គការសហប្រជាជាតិ និងប្រទេសហូឡង់ដែលក្រុមប្រឹក្សានេះអាចទទួលយកបាន ហើយកំណត់ទៀតថាតុលាការអន្តរជាតិអាចតាំងនៅទីកន្លែងដែលខ្លួនគិតថា ជាការចាំបាច់ក្នុងការដំណើរការការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព..."។

អូន[64] ឯកសារនានាស្តីពីការបង្កើត អ.វ.ត.ក ពុំអនុញ្ញាតឲ្យមានការពង្រីកវិសាលភាពនៃបន្ទប់សវនាការដើម្បីអនុវត្តនីតិវិធីនៅខាងក្រៅឡើយ។ វិធាន ៥(១) នៃវិធានផ្ទៃក្នុងចែងថា អ.វ.ត.ក អាច "ស្នើសុំ" ជំនួយតាមផ្លូវតុលាការ ពីសំណាក់រដ្ឋនានាដែលពុំមែនជាភាគីនៃកិច្ចព្រមព្រៀង។ ការស្នើសុំជំនួយតាមផ្លូវតុលាការ ពុំសមមាត្រទៅនឹងការធ្វើប្រតិបត្តិការតាមផ្លូវតុលាការរបស់ អ.វ.ត.ក នៅក្រៅប្រទេសឡើយ។ ប៉ុន្តែមេធាវីការពារក្តីសូមទទួលស្គាល់ថា កាលពីពេលកន្លងមក ក.ស.ច.ស ធ្លាប់បានទៅបំពេញការងារតាមផ្លូវតុលាការនៅប្រទេសបារាំង ។

30. ទោះបី អ.វ.ត.ក ត្រូវបានអនុញ្ញាតឲ្យពង្រីកវិសាលភាពនៃបន្ទប់សវនាការរបស់ខ្លួនទៅក្រៅប្រទេសកម្ពុជា ក្នុងគោលបំណងស្តាប់សក្ខីកម្មសាក្សីដែលមានលេខសម្គាល់ TCE-38 តាមរយៈប្រព័ន្ធសោតទស្សន៍ក៏ដោយ ក៏នៅមានបញ្ហាមួយពស្តុភារមួយចំនួនដែលត្រូវពិចារណាដែលបញ្ហាទាំងនោះអាចឲ្យសក្ខីកម្មរបស់សាក្សី TCE-38 តាមរយៈប្រព័ន្ធសោតទស្សន៍មិនអាចធ្វើទៅបាន។ សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍នាំឲ្យមានការពន្យារពេល និងខាតពេលសវនាការឥតប្រយោជន៍។ ជាក់ស្តែង ការស្តាប់សក្ខីកម្មរបស់សាក្សីឈ្មោះ ឡុង នរិន្ទ តាមប្រព័ន្ធសោតទស្សន៍បានចំណាយពេលសវនាការឥតប្រយោជន៍ បន្ទាប់ពីមានបញ្ហាក្នុងការតភ្ជាប់ប្រព័ន្ធសោតទស្សន៍មួយពេល។ សូម្បីតែនៅពេលប្រព័ន្ធសោតទស្សន៍បានដំណើរការវិញក៏ដោយ ក៏នៅមានការអូសបន្លាយពេល និងសំឡេងឡូងរំខានក្នុងពេលសួរនិងឆ្លើយ។

31. ប៉ុន្តែសំខាន់ជាងនេះទៀត មានបញ្ហាជាច្រើនដែល អង្គជំនុំជម្រះសាលាដំបូងត្រូវតែយកមកពិចារណា។ ឧទាហរណ៍ តើសាក្សី TCE-38 គួរតែផ្តល់សក្ខីកម្មពីកន្លែងណា[65]? តើមន្ត្រីសហរដ្ឋអាមេរិក ឬមន្ត្រីកម្ពុជាជាអ្នកគ្រប់គ្រងការធ្វើសម្បថ? ប្រសិនបើសាក្សី TCE-38 ផ្តល់សក្ខីកម្មមិនពិតដូចតាមសម្បថ តើគាត់ត្រូវទទួលខុសត្រូវក្រោមច្បាប់សហរដ្ឋអាមេរិក ឬច្បាប់កម្ពុជា? ប្រសិន

---

[62] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប លេខ 955 (S/RES/955 (1994), ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤) គូសបញ្ជាក់ថាក្រុមប្រឹក្សាសន្តិសុខ "បានពិចារណាទៅលើការណ៍ដែលថា តុលាការអន្តរជាតិអាចរៀបចំក្រៅពីទីតាំងរបស់ខ្លួនបាននៅពេលខ្លួនពិចារណាឃើញថាជាការចាំបាច់ដើម្បីដំណើរការការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព ..."។

[63] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៣។

[64] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសៀរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន, មាត្រា ១០។

[65] *សូមមើល* សេចក្តីសម្រេចលើបញ្ហាសោតទស្សន៍ក្នុងសំណុំរឿង *Tadić* កថាខណ្ឌ ២២ ដែលតម្រូវថាប្រសិនបើរៀបចំធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ គេត្រូវធានាឲ្យបាននូវបែបបទនៃកិច្ចដំណើរការនីតិវិធីនៅទីកន្លែងនោះ និងគួរតែជ្រើសរើសយកស្ថានទូត ស្ថានកុងស៊ុល ឬអគារតុលាការយកមកប្រើប្រាស់ដើម្បីធ្វើសក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។

បើគាត់ទទួលខុសត្រូវក្រោមច្បាប់កម្ពុជា តើ អ.វ.ត.ក ឬ តុលាការកម្ពុជាជាអ្នកអនុវត្តច្បាប់នោះឲ្យមានប្រសិទ្ធភាព? នៅចំពោះមុខ បញ្ហាទាំងនេះ មេធាវីការពារក្ដីសូមអះអាងថា ការផ្ដល់សក្ខីកម្មរបស់សាក្សី TCE-38 តាមប្រព័ន្ធសោតទស្សន៍ ត្រូវមានទម្ងន់ជាភស្តុតាងតិចបំផុត មិនដូចការផ្ដល់សក្ខីកម្មរបស់គាត់ដោយឆ្លងកាត់ការធ្វើសម្បថនៅ អ.វ.ត.ក ឡើយ[66]។

**ឃ. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថាសាក្សី TCE-38 អាចផ្ដល់សក្ខីកម្មតាមរយៈសោតទស្សន៍មែននោះ សមាជិកនៃក្រុមមេធាវីការពារក្ដីគួរតែបានទទួលការអនុញ្ញាតឲ្យសួរដេញដោលគាត់ដល់ទីកន្លែងដែលគាត់ផ្ដល់សក្ខីកម្ម**

32. ដើម្បីការពារសិទ្ធិរបស់លោក អៀង សារី ឲ្យបានជាអតិបរមា និងកុំឲ្យមានការកាត់បន្ថយនូវសិទ្ធិនេះក្នុងករណីមិនចាំបាច់បំផុតនោះ សមាជិកមួយចំនួននៃក្រុមមេធាវីការពារក្ដីត្រូវតែបានទទួលការអនុញ្ញាតឲ្យសួរដេញដោលសាក្សី TCE-38 ដល់ទីកន្លែងដែលគាត់ផ្ដល់សក្ខីកម្ម ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា សាក្សី TCE-38 អាចផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍។ ចំណុចនេះនឹងជួយការពារសិទ្ធិលោក អៀង សារី ដោយសារវានឹងជួយក្រុមមេធាវីការពារក្ដីក្នុងការវាយតម្លៃពីភិនភាគ និងឥរិយាបថរបស់សាក្សី TCE-38 ដោយអនុញ្ញាតឲ្យមានការសួរដេញដោលដោយផ្អែកលើការវាយតម្លៃទាំងអស់នេះ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង *Bagosora* ធ្លាប់បានកត់សម្គាល់រួចមកហើយថា៖ “ការតំណាងរបស់ភាគីនៅក្នុងពេលសក្ខីកម្មត្រូវបានបញ្ជូនតាមរលកធាតុអាកាស ធានាបានថាលក្ខខណ្ឌនានានៃការផ្ដល់សក្ខីកម្មពិតជាមិនលម្អៀង និងត្រឹមត្រូវ”[67]។

**អាស្រ័យហេតុនេះ** តាមសំអាងហេតុទាំងប៉ុន្មានខាងលើ មេធាវីការពារក្ដីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖ **បង្គាប់** អោយ កសព បញ្ឈប់ការប្រាស្រ័យ*ទាក់ទងដោយភាគីតែម្ខាង* ជាមួយសាក្សី TCE-38។ **បដិសេធ**សំណើរបស់ ក.ស.ព ស្នើសុំឲ្យសាក្សី TCE-38 ផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ឬជាជម្រើសផ្សេងពីនេះ **អនុញ្ញាត**ឲ្យសមាជិកនៃក្រុមមេធាវីការពារក្ដីធ្វើដំណើរទៅកាន់ទីតាំងរបស់សាក្សី TCE-38 ដើម្បីធ្វើការសួរដេញដោល។

---

[66] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២១។

[67] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Bagosora និងអ្នកដទៃទៀត*, លេខសំណុំរឿង, ICTR-98-41-T, សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាស្នើសុំឲ្យសាក្សី BT ផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍, ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៤, កថាខណ្ឌ ១១។

សូមលោកលោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តីលោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានា**ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២**